Office of Evaluation, Research & Accountability
2nd Floor Portal A
440 N. Broad Street
Philadelphia, PA 19130

ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០២៣

ជូនចំពោះ មាតាបិតា និងអាណាព្យាបាល របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

យើងសរសេរលិខិតនេះដើម្បីជម្រាបលោកអ្នកថា **សិស្សថ្នាក់ទី ៣ ដល់ ទី ៨ នឹងចូលរួមក្នុង ការប្រឡងតាមប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋផិនស៊ីលវេនញ៉ា (PSSA) រវាងថ្ងៃទី ២៤ ខែ មេសា ដល់ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២៣។**

PSSA គឺជាឧបករណ៍ដ៏សំខាន់ដែលផ្តល់ព័ត៌មានជិតដល់អំពីការរីកចម្រើនក្នុងការសិក្សារបស់សិស្សលោកអ្នក។ ពិន្ទុរបស់សិស្សម្នាក់ៗជួយគ្រូកំណត់ពីចំណុចខ្លាំង និងចំណុចដែលត្រូវការការលូតលាស់ របស់ក្មេង ដែលអនុញ្ញាតឱ្យគ្រូរៀបចំការបង្ហាត់បង្រៀនរបស់ក្មេងរៀងៗខ្លួន ដើម្បីជួយដល់ការលូតលាស់របស់ពួកគេឱ្យបានល្អបំផុត។ ពិន្ទុ PSSA ក៏ផ្តល់ព័ត៌មានដល់សាលា និងក្រសួងអប់រំ ដើម្បីគាំទ្រការកែលម្អ និងរៀបចំផែនការជុំវិញកម្មវិធីសិក្សា និងការបង្ហាត់បង្រៀន។

PSSA ត្រូវបានកំណត់ដោយរដ្ឋ ហើយការចូលរួមដោយសិស្សទាំងអស់នៅថ្នាក់ទី ៣ ដល់ ទី ៨ គឺតម្រូវដោយច្បាប់សហព័ន្ធ។ សាលានីមួយៗត្រូវមានសិស្សចំនួន ៩៥% ប្រឡង ភាសាអង់គ្លេស គណិតវិទ្យា និង វិទ្យាសាស្ត្រ (សម្រាប់ថ្នាក់ទី ៤ និង ទី ៨)។ ប្រសិនបើសាលាមានការចូលរួមក្រោម ៩៥% នោះពិន្ទុនៃការវាយតម្លៃរបស់រដ្ឋសម្រាប់សាលានឹងរងផលប៉ះពាល់អវិជ្ជមាន។ ក្នុងអំឡុងពេលប្រឡង គឺជាការសំខាន់បំផុតសម្រាប់សិស្សានុសិស្សដែលត្រូវមករៀនជារៀងរាល់ថ្ងៃ និងបន្តចុះឈ្មោះក្នុងសាលាបច្ចុប្បន្នរបស់ពួកគេ។ ដោយមូលហេតុនេះ សំណើផ្ទេររដ្ឋបាលនឹងត្រូវពន្យារពេលរហូតដល់ចុងបញ្ចប់នៃរយៈពេលប្រឡង ដោយមានករណីលើកលែងតិចតួចបំផុត។

ឯកសារដែលភ្ជាប់ខាងក្រោមនេះ ផ្តល់នូវព័ត៌មានសំខាន់ៗអំពី PSSA នាពេលខាងមុខនេះ។ សូមពិនិត្យមើលដោយប្រុងប្រយ័ត្ន។ លោកអ្នកក៏គួរតែទទួលបានច្បាប់ចម្លងនៃឯកសារទាំងនេះពីសាលារបស់កូនលោកអ្នក ហើយឯកសារទាំងនេះក៏អាចរកឃើញនៅលើគេហទំព័ររបស់យើង PSSA website។

- **PSSA Parent Guide**: ការពិពណ៌នាទូទៅខ្លីៗនៃ PSSA ជាមួយនឹង បណ្តាញតភ្ជាប់ (links) ទៅកាន់ប្រភពជំនួយសម្រាប់មាតាបិតារបស់ក្រសួងអប់រំ។
- **Frequently Asked Questions**: ទំព័រនៃព័ត៌មានសំខាន់ៗពីក្រសួងអប់រំរដ្ឋ ផិនស៊ីលវេនញ៉ា ដែលផ្តល់ចម្លើយចំពោះសំណួរដែលគេឧស្សាហ៍សួរ។
- **PSSA Test Features and Accommodations**: ការពន្យល់អំពីលក្ខណៈពិសេសនៃការប្រឡង និងការជួយសម្របសម្រួលទៅតាមសេចក្តីត្រូវការ រួមទាំងបណ្តាញតភ្ជាប់ទៅកាន់ការណែនាំអំពីការជួយសម្របសម្រួលទៅតាមសេចក្តីត្រូវការ។

- **Code of Conduct for Test Takers**: អ្វីដែលគួរធ្វើ និងអ្វីដែលមិនគួរធ្វើ សម្រាប់សិស្សក្នុងអំឡុងពេលធ្វើតេស្ត។

- **Electronic Devices Parent Letter**: លិខិតទៅកាន់ក្រុមគ្រួសាររៀបរាប់លម្អិតអំពីច្បាប់របស់ក្រសួងអប់រំអប់រំរដ្ឋ ផិនស៊ីលវេនញ៉ា និងផលវិបាកនៃការប្រើប្រាស់ទូរស័ព្ទដៃ និងឧបករណ៍អេឡិចត្រូនិកផ្សេងទៀតក្នុងអំឡុងពេលធ្វើតេស្ត។

ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី ការប្រឡងតាមប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋផិនស៊ីលវេនញ៉ា (PSSA) សូមមើលគេហទំព័រ website របស់ ក្រសួងអប់រំរដ្ឋផិនស៊ីលវេនញ៉ា។ ប្រសិនបើលោកអ្នកមានសំណួរទូទៅអំពីការវាយតម្លៃរបស់ក្រសួងអប់រំ សូមទាក់ទង ការិយាល័យ វាយតម្លៃ ស្រាវជ្រាវ និងទទួលខុសត្រូវ។ តាមរយៈនៃលិខិតទំនាក់ទំនងរបស់យើង (via our contact form)។

ដោយសេចក្ដីស្មោះស្ម័គ្រ

Dr. Tonya Wolford
*ប្រធាន – ផ្នែកវាយតម្លៃ ស្រាវជ្រាវ និងទទួលខុសត្រូវ*